ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ ៤២២ សាល-១៧ អអក

ភ្នំពេញ, ថ្ងៃទី២៧ ខែមិនា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីការពិគ្រោះយោបល់សាធារណៈលើសេចក្តីព្រាង អាជ្ញាបណ្ណផលិតកម្មរបស់ក្រុមហ៊ុន រូយ ហ្វេង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជនគ្រប់រូប ដែលរស់នៅភូមិពោធិ៍ទាប ឃុំម្លូរព្រៃមួយ ស្រុកឆែប ខេត្តព្រះវិហារ ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងនឹងចេញអាជ្ញាបណ្ណផលិតកម្មឲ្យក្រុមហ៊ុន រូយ ហ្វេង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត ដើម្បីធ្វើសេវាកម្មផលិតអគ្គិសនីដើរដោយថាមពលជីវម៉ាស់ ដែលមានទីតាំងផលិត នៅភូមិពោធិ៍ទាប ឃុំម្លូរព្រៃមួយ ស្រុកឆែប ខេត្តព្រះវិហារ អានុភាពសរុប ៤,៥ម៉េហ្គាវ៉ាត់ អនុលោមតាមកិច្ចព្រមព្រៀងទិញ-លក់អគ្គិសនី រវាងអគ្គិសនីកម្ពុជា និងក្រុមហ៊ុន រូយ ហ្វេង (ខេមបូឌា) អ៊ិនធើណេ សិនណល ខមភេនី លីមីធីត ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ តាមខ្លឹមសារសេចក្តីព្រាងលក្ខខណ្ឌអាជ្ញាបណ្ណ ដែលជូនភ្ជាប់មកជាមួយនេះ ។ តាមនីតិវិធីក្នុងការចេញអាជ្ញាបណ្ណរបស់អាជ្ញាធរអគ្គិសនីកម្ពុជា សាធារណជនគ្រប់រូបមានសិទ្ធិពិនិត្យ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាលើខ្លឹមសារនៃអាជ្ញាបណ្ណផលិតកម្មដែលគ្រោងនឹងផ្តល់ឲ្យក្រុមហ៊ុននេះ ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងលក្ខខណ្ឌអាជ្ញាបណ្ណនៅ.................................................................................................................... សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជនរស់នៅភូមិពោធិ៍ទាប ឃុំម្លូរព្រៃមួយ ស្រុកឆែប ខេត្តព្រះវិហារ ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញអាជ្ញាបណ្ណឲ្យក្រុមហ៊ុន រូយ ហ្វេង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត អាចអញ្ជើញមកទីកន្លែងខាងលើ ដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា ចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះរហូតដល់ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៧ ។

អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា " **អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានហេតុផលច្បាស់លាស់ប៉ុណ្ណោះ** " ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

បណ្ឌិត.ឌី និរន្ទ

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
**ទូរស័ព្ទ** : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ **ទូរសារ** : ០២៣ ២១៤ ១៤៤, **អ៊ីម៉ែល** : admin@eac.gov.kh ; Website : www.eac.gov.kh

សេចក្តីព្រាង
សម្រាប់ពិគ្រោះយោបល់ពីថ្ងៃជូនដំណឹង
រហូតដល់ថ្ងៃទី.......ខែ..........ឆ្នាំ២០១៧

# អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA

# ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
**ELECTRICITY LAW OF THE KINGDOM OF CAMBODIA**

# អាជ្ញាបណ្ណផលិតកម្ម
## សម្រាប់ធ្វើសេវាកម្មផលិតកម្មអគ្គិសនី ដើរដោយថាមពល ជីវម៉ាស់ អានុភាពសរុប ៤,៥ មេហ្គាវ៉ាត់ នៅភូមិពោធិ៍ទាប ឃុំម្លូរព្រៃមួយ ស្រុកឆែប ខេត្តព្រះវិហារ

# GENERATION LICENSE
## FOR PROVIDING ELECTRIC POWER GENERATION SERVICE FROM BIOMASS WIT THE CAPACITY 4.5 MW AT POR TEAB VILLAGE, MLU PREY MUOY COMMUNE, CHHAEB DISTRICT, PREAH VIHEAR PROVINCE.

ក្រុមហ៊ុន រួយ ហ្វេង (ខេមបូឌា) អ៊ិនធើណេសិនណល ខមភេនី លីមីធីត
**RUI FENG (CAMBODIA) INTERNATIONAL COMPANY LIMITED**

ថ្ងៃទី... ខែ... ឆ្នាំ...

..., ...

# ផ្នែកទី ១
# សេចក្តីសម្រេចផ្តល់អាជ្ញាបណ្ណផលិតកម្ម
# សម្រាប់ក្រុមហ៊ុន រួយ ហ្វេង (ខេមបូឌា) អ៊ិនធើណេសិនណាល ខមភេនី លីមីធីត

# PART 1
# DECISION TO GRANT THE GENERATION LICENSE
# TO RUI FENG (CAMBODIA) INTERNATIONAL COMPANY LIMITED